ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃព្រហស្បតិ៍ ១០កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី២ ខែតុលា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៥៥ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៤៦៧លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីក្នុងខែកញ្ញា ឆ្នាំ២០២៥

ក្នុងខែកញ្ញា ឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសម្រេចចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន**៥៥គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ**៤៦៧លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**៣៧ពាន់កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៣៨គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១៧គម្រោង។ ក្នុងរយៈពេល៩ខែនៃឆ្នាំ២០២៥នេះ គ.វ.ក. បានសម្រេចចុះបញ្ជីគម្រោងវិនិយោគចំនួន **៥៤៦គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ **៧,៨ប៊ីលានដុល្លារអាម៉េរិក** គឺគម្រោងវិនិយោគមានការកើនឡើងចំនួន **២៣១គម្រោង** ស្មើនឹងប្រមាណ **៧៣%** ខណៈទុនវិនិយោគមានការកើនឡើងប្រមាណ **២,៥ប៊ីលានដុល្លារអាម៉េរិក** ស្មើនឹងប្រមាណ **៤៧%** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ ដែល គ.វ.ក. បានចុះបញ្ជីគម្រោងវិនិយោគត្រឹមតែ ៣១៥គម្រោង ក្នុងទំហំទុនវិនិយោគប្រមាណ ៥,៣ប៊ីលានដុល្លារអាម៉េរិក។ ជាការកត់សម្គាល់ ត្រឹមតែរយៈពេល៩ខែ គ.វ.ក បានចុះបញ្ជីគម្រោងវិនិយោគលើសការចុះបញ្ជីគម្រោងវិនិយោគពេញមួយឆ្នាំ២០២៤ រហូតដល់ទៅ ១៣២គម្រោង។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែកញ្ញា ឆ្នាំ២០២៥ មានដូចខាងក្រោម៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| កសិកម្ម និងកសិ-ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រកែច្នៃដំឡូងមី និងផលិតផលជី**<br>- ទីតាំង៖ ស្រុកស្ទោង ខេត្តកំពង់ធំ<br>- ទំហំទុនវិនិយោគប្រមាណ៖ ២០លានដុល្លារអាម៉េរិក<br>- ការបង្កើតការងារ៖ ៩០កន្លែង។ |
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំដំឡើងរថយន្ត**<br>- ទីតាំង៖ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង<br>- ទំហំទុនវិនិយោគប្រមាណ៖ ១៩លានដុល្លារអាម៉េរិក<br>- ការបង្កើតការងារ៖ ១.១៤២កន្លែង។ |

### ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រវាយនភ័ណ្ឌ កាត់ដេរ និងផលិតផលពាក់ព័ន្ធនឹងវាយនភ័ណ្ឌ**<br>- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ឃីលូ ជាន ពុ ចាយ ស្ថិតនៅខេត្តស្វាយរៀង<br>- ទំហំទុនវិនិយោគប្រមាណ៖ ៣០លានដុល្លារអាម៉េរិក<br>- ការបង្កើតការងារ៖ ១.០៧៨កន្លែង។ |

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែកញ្ញា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៥៥** (១៧ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៤៦៧** លាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៣៧ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)



**៣៥លាន** កសិកម្ម និង កសិឧស្សាហកម្ម

**៩១លាន** ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**៣៤១លាន** ឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៥៦,០០% |
| 2. កោះ British Virgin | ១៩,៤៣% |
| 3. កម្ពុជា | ១២,៨៧% |
| 4. សិង្ហបុរី | ៦,៧៩% |
| 5. កោះ Samoa | ២,៨២% |
| 6. វៀតណាម | ១,៨៨% |
| 7. សហរដ្ឋអាម៉េរិក | ០,២២% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ១១+
- ៦-១០
- ១-៥
- មិនមាន

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគចាប់ពី ខែមករា ដល់ខែកញ្ញា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៥៤៦** (២១៤ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៧,៨** ប៊ីលាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៣៧៦ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)

**៤០៥លាន** កសិកម្ម និង កសិឧស្សាហកម្ម

**១,៩ប៊ីលាន** ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**១៧៥លាន** ទេសចរណ៍

**៥,៣ប៊ីលាន** ឧស្សាហកម្ម



## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៥២,៩៦% |
| 2. កម្ពុជា | ៣០,១៥% |
| 3. សិង្ហបុរី | ៦,៩៣% |
| 4. វៀតណាម | ៥,២៤% |
| 5. កោះ British Virgin | ២,០១% |
| 6. អង់គ្លេស | ០,៦៣% |
| 7. កោះ Cayman | ០,៥១% |
| 8. កោះ Samoa | ០,៤២% |
| 9. Bermuda | ០,៣៣% |
| 10. សហរដ្ឋអាមេរិក | ០,២៩% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ៦១+
- ៣១-៦០
- ១-៣០
- មិនមាន